ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**ប្រធានគណៈមេធាវី**

មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ឹង គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ុច ប៊ុលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុភន្ទូន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានន្ទ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី ឃឹម វិស្សុត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហួ លីហួរ

២៣-មេធាវី វ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ ៖ ០៩៦ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៦

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងលេខាព័ត៌មានគណៈមេធាវី

### ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨

-យោងតាមសំណើរបស់សាមីខ្លួន ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦

-យោងតាមការចាំបាច់របស់គណៈមេធាវី ។

## ស ម្រេ ច

**ប្រការ ១.-** ត្រូវបានតែងតាំងកញ្ញា **អ៊ិត ច័ន្ទគុជនី** ជាលេខាព័ត៌មានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា **គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ នេះតទៅ ។**


អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២..** កញ្ញា **អ៊ិត ច័ន្ទគុជ្ជនី** ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែចំនួន **១៥០ (មួយរយហាសិប) ដុល្លារអាមេរិក** ក្នុងមួយខែ។

**ប្រការ ៣..** កញ្ញា **អ៊ិត ច័ន្ទគុជ្ជនី** មានតួនាទី និងភារកិច្ចដូចតទៅ ៖

- បដិសណ្ឋារកិច្ចចំពោះភ្ញៀវជាតិ និងអន្តរជាតិ ដែលមកទំនាក់ទំនងការងារជាមួយគណៈមេធាវី
- សហការជាមួយផ្នែកផ្សេងៗក្នុងការដោះស្រាយបញ្ហានានា
- ទទួលទូរស័ព្ទដែលហៅចូលមក រួចភ្ជាប់ទៅផ្នែកដែលគេចង់ទំនាក់ទំនង
- រៀបចំទីកន្លែងអាហារសម្រន់សម្រាប់ការប្រជុំក្រុមប្រឹក្សាគណៈមេធាវី និងគណៈកម្មការនានារបស់គណៈមេធាវី
- ចាត់ចែងសំអាត និងតុបតែងសោភ័ណ្ឌភាព
- ស្រង់ព័ត៌មានគ្រប់ប្រភេទដែលបានទទួលពីប្រភពនានា និងធ្វើសេចក្តីរាយការណ៍ជូនប្រធាន នាយកដ្ឋានរដ្ឋបាល
- រៀបចំ និងគ្រប់គ្រងបញ្ជីវត្តមានសមាជិក-សមាជិកាគណៈមេធាវី និងសិស្សមេធាវី នៅពេលសិក្ខាសាលា ឬក្នុងកម្មវិធីផ្សេងៗ
- ធ្វើការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំគណៈមេធាវី។

**ប្រការ ៤..** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥..** អគ្គលេខាធិការ អគ្គហេរញ្ញិក នាយកដ្ឋានរដ្ឋបាល និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះតាមមុខការរៀងៗខ្លួន ៕

**មេធាវី. ប៊ុន_ហុន**

**ចម្លងជូន** :

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ